# ធនាគារ អេស៊ីលីដា ភីអិលស៊ី
# ACLEDA Bank Plc.

**ការិយាល័យកណ្ដាល**

## ធនាគារ អេស៊ីលីដា ភីអិលស៊ី ទទួលបានការដំឡើងចំណាត់ថ្នាក់ Stand-Alone Credit Profile (SACP) ពីកម្រិត 'bb-' ទៅកម្រិត 'bb' ពីភ្នាក់ងារវាយតម្លៃអន្តរជាតិ Standard & Poor's (S&P) Global Ratings

**ធនាគារ អេស៊ីលីដា ភីអិលស៊ី** មានកិត្តិយស សូមអនុញ្ញាតជម្រាបជូនដល់អតិថិជន និង សាធារណជនទាំងអស់ មេត្តាទទួលជ្រាបថា នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២០ ធនាគារ អេស៊ីលីដា បានទទួលការដំឡើងចំណាត់ថ្នាក់ Stand-Alone Credit Profile (SACP) ពីកម្រិត 'bb-' ទៅកម្រិត 'bb' ពីភ្នាក់ងារវាយតម្លៃអន្តរជាតិ Standard & Poor's (S&P) Global Ratings ។

**បណ្ឌិត អ៊ិន ចាន់នី** ប្រធាននាយកប្រតិបត្តិ ធនាគារ អេស៊ីលីដា ភីអិលស៊ី បានមានប្រសាសន៍ថា ការដំឡើងចំណាត់ថ្នាក់ (SACP) ពីកម្រិត 'bb-' ទៅកម្រិត 'bb' ដល់ ធនាគារ អេស៊ីលីដា ដោយមូលហេតុចម្បងៗ ដូចជា ធនាគាររក្សាបាននូវទ្រព្យសកម្មចម្រុះ ការគ្រប់គ្រងដោយការប្រុងប្រយ័ត្ន គិតគូរនូវរាល់ហានិភ័យពាក់ព័ន្ធជាមូលដ្ឋានសម្រាប់ការលូតលាស់ និងមានមូលធនភាវូបនីយកម្មរឹងមាំ។ កត្តាទាំងអស់នេះឆ្លុះបញ្ចាំងអំពីភាពរឹងមាំនៃបណ្ដាញធុរកិច្ចរបស់ធនាគារ អេស៊ីលីដា ដោយរក្សាបាននូវចំណូលប្រកបដោយចីរភាព ដោយ មិនមានផលប៉ះពាល់។

ទស្សនវិស័យស្ថិរភាពដែលបង្ហាញនៅក្នុងចំណាត់ថ្នាក់នេះ ឆ្លុះបញ្ចាំងពីភាពរឹងមាំនៃហិរញ្ញវត្ថុជាមួយនឹងទ្រនាប់ដើមទុនគ្រប់គ្រាន់ ដើម្បីស្ថិរភាពនៃដំណើរការអាជីវកម្ម។

**សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងតាមរយៈ ធនាគារ អេស៊ីលីដា ភីអិលស៊ី**


លោកស្រី **ម៉ារ អមរា**

មុខងារ : អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយិកាប្រតិបត្តិហិរញ្ញវត្ថុ (មន្ត្រីទំនាក់ទំនងសាធារណៈ)

ទូរស័ព្ទ : ០១៥ ៩០០ ១២៦

អ៊ីម៉ែល : amara@acledabank.com.kh

លោកស្រី **ប៊ុត ប៊ុនសីហា**

មុខងារ : អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយិកាប្រតិបត្តិនីតិកម្ម និងលេខាធិការក្រុមហ៊ុន (មន្ត្រីទទួលបន្ទុកផ្ដល់ព័ត៌មាន)

ទូរស័ព្ទ :០១៥ ៦០០ ៥៣២

អ៊ីម៉ែល : buth.bunsayha@acledabank.com.kh


ថ្ងៃព្រហស្បតិ៍ ៣កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០

**ធនាគារ អេស៊ីលីដា ភីអិលស៊ី**